positive partnerships

Working together to support school-aged students on the autism spectrum

# តើអ្នកណាអាចជួយបាន?

Khmer - Who can help?



**ប្រសិនបើអ្នកព្រួយបារម្ភអំពីការអភិវឌ្ឍន៍របស់កូនអ្នក ការពិភាក្សាជាមួយអ្នកមានវិជ្ជាជីវៈអាចជួយអ្នក និងកូនរបស់អ្នកបាន។ ព័ត៌មាននេះពន្យល់ពីអ្វីដែលអ្នកមានវិជ្ជាជីវៈនានាធ្វើ ដើម្បីផ្តល់ការគាំទ្រ។**

## វេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GP)

GP គឺជាវេជ្ជបណ្ឌិតដែលធ្វើការជាមួយមនុស្សគ្រប់វ័យ។ GP អាចជួយក្នុងការវាយតម្លៃតម្រូវការសុខភាពផ្លូវកាយ និងផ្លូវចិត្តសម្រាប់អ្នក និងកូនរបស់អ្នក។ នៅប្រទេសអូស្ត្រាលី ជាញឹកញាប់អ្នកត្រូវទៅជួប GP របស់អ្នក ដើម្បីទទួលបានការបញ្ជូនបន្តទៅអ្នកមានវិជ្ជាជីវៈជាច្រើនទៀត។

## អ្នកចិត្តសាស្ត្រ

អ្នកចិត្តសាស្ត្រ (ជួនកាលគេហៅថា 'ចិត្តសាស្ត្រ' ឬ ‘psychs’) អាចជួយមនុស្សនៅពេលពួកគេមានបញ្ហាជាមួយនឹងការគិត អារម្មណ៍ ការរៀនជំនាញថ្មីៗ ឬអាកប្បកិរិយារបស់ពួកគេ។ ជួនកាលអ្នកចិត្តសាស្ត្រធ្វើការជាមួយមនុស្សជាក្រុម ហើយជាញឹកញាប់ ពួកគេនឹងនិយាយជាមួយមនុស្សដោយខ្លួនឯង។ ពួកគេអាចជួយគាំទ្រឪពុកម្តាយ និងកូនៗដោយប្រើគំនិត និងយុទ្ធសាស្ត្រថ្មីៗដើម្បីសាកល្បង ដែលប្រហែលជាអាចជួយបាន។



## គ្រូពេទ្យកុមារ

គ្រូពេទ្យកុមារគឺជាវេជ្ជបណ្ឌិតដែលមានឯកទេសក្នុងការថែទាំសុខភាពទារក កុមារ និងក្មេងជំទង់។ ពួកគេអាចធ្វើការនៅក្នុងមន្ទីរពេទ្យ ឬនៅក្នុងសហគមន៍។ ពួកគេក៏អាចបញ្ជូនបន្តកូនរបស់អ្នក ទៅអ្នកមានវិជ្ជាជីវៈផ្សេងទៀតសម្រាប់ការគាំទ្របន្ថែមដែរ។

## អ្នកជំនាញខាងសោតទស្សន៍

អ្នកជំនាញខាងសោតទស្សន៍ គឺជាអ្នកឯកទេសដែលអាចរកមើល ថាតើមនុស្សមានបញ្ហាក្នុងការស្តាប់ឬអត់ ហើយជាញឹកញាប់ អាចជួយកែលម្អការស្តាប់របស់មនុស្សបាន។

## គ្រូពេទ្យផ្នែកវិកលចរិត

គ្រូពេទ្យផ្នែកវិកលចរិត គឺជាវេជ្ជបណ្ឌិតដែលមានឯកទេសផ្នែកសុខភាពផ្លូវចិត្ត។ គ្រូពេទ្យផ្នែកវិកលចរិតធ្វើរោគវិនិច្ឆ័យ ព្យាបាល និងជួយគាំទ្រភាពខុសៗគ្នាខាងផ្លូវចិត្ត ផ្លូវអារម្មណ៍ និងអាកប្បកិរិយា។ ពួកគេធ្វើការតាមរបៀបផ្សេងៗគ្នា ហើយអាចប្រើវិធីសាស្ត្រចម្រុះរួមទាំងការប្រឹក្សា និងឱសថ។

ចូលទៅកាន់គេហទំព័រ **positivepartnerships.com.au**

The Positive Partnerships initiative is funded by the Australian Government Department of Education through the Helping Children with Autism Package. The views expressed in this publication do not necessarily represent the views of the Australian Government or the Australian Government Department of Education.

# តើអ្នកណាអាចជួយបាន?

## អ្នកព្យាបាលរោគដោយកាយវប្បកម្ម

អ្នកព្យាបាលរោគដោយកាយវប្បកម្ម (ជួនកាលគេហៅថា physios) ធ្វើការជាមួយមនុស្សគ្រប់វ័យដែលត្រូវការជំនួយផ្នែកឆ្អឹង សាច់ដុំ និងផ្នែកផ្សេងទៀតនៃរាងកាយរបស់ពួកគេ។ Physios អាចជួយគាំទ្រមនុស្សជាមួយនឹងការធ្វើលំហាត់ប្រាណជាក់លាក់ ឬជំនួយរាងកាយ ដែលជួយពួកគេគ្រប់គ្រងបានកាន់តែប្រសើរ។

## អ្នកព្យាបាលអ្នកជំងឺដោយធ្វើសកម្មភាពផ្សេងៗ

អ្នកព្យាបាលអ្នកជំងឺដោយធ្វើសកម្មភាពផ្សេងៗ (ជួនកាលគេហៅថា OTs) ជួយកូនរបស់អ្នកឱ្យចូលរួមក្នុងសកម្មភាពប្រចាំថ្ងៃរួមមាន៖

- មើលថែខ្លួនឯង - ឧទាហរណ៍៖ ការញ៉ាំម្ហូបខ្លួនឯង ការស្លៀកពាក់ ការដុសធ្មេញ ការទៅបង្គន់
- ការចូលរួមក្នុងសកម្មភាពនានានៅផ្ទះ សាលារៀន កន្លែងធ្វើការ និងនៅក្នុងសហគមន៍ - ឧទាហរណ៍៖ ការសរសេរ ការប្រើកន្ត្រៃ ការទប់ទល់ដោះស្រាយ ភាពខុសគ្នាខាងវិញ្ញាណ (ឧទាហរណ៍ ប្រតិកម្មនឹងអាហារ សំឡេងខ្លាំង ពន្លឺខ្លាំង។ល។) ការប្រើយានដឹកជញ្ជូនសាធារណៈ។
- ការចូលរួមក្នុងសកម្មភាពនានាដែលពួកគេចូលចិត្ត ឧទាហរណ៍៖ ការលេងជាមួយអ្នកឯទៀត ការភ្ជាប់ទំនាក់ទំនងជាមួយអ្នកឯទៀតដែលមានចំណាប់អារម្មណ៍ស្រដៀងគ្នា។ OT's ក៏អាចផ្តល់ឧបករណ៍ ឬការគាំទ្រនានា ដើម្បីជួយមនុស្សចូលរួមក្នុងសកម្មភាពដែលពួកគេចូលចិត្តផងដែរ។

## បុគ្គលិកសង្គមកិច្ច

បុគ្គលិកសង្គមកិច្ចអាចជួយមនុស្សទប់ទល់ដោះស្រាយបញ្ហានានា និងណែនាំពួកគេនៅពេលប្រឈមនឹងបញ្ហា។ បុគ្គលិកសង្គមកិច្ចអាចជួយក្នុងការគ្រប់គ្រងអាទិភាព និងជួយមនុស្សស្វែងរកការគាំទ្រត្រឹមត្រូវ។

## អ្នកជំនាញរោគសាស្ត្រខាងការនិយាយស្តី/ អ្នកព្យាបាលរោគ

អ្នកជំនាញរោគសាស្ត្រខាងការនិយាយស្តី ជួយមនុស្សក្នុងការប្រាស្រ័យទាក់ទង។ ការប្រាស្រ័យទាក់ទងទាក់ទិនច្រើនជាងការនិយាយ និងការស្តាប់។ វាក៏ពាក់ព័ន្ធនឹងការស្តាប់ ការយល់ដឹង ជំនាញសង្គម ការអាន ការសរសេរ និងការប្រើសំឡេងផងដែរ។ អ្នកជំនាញរោគសាស្ត្រខាងការនិយាយស្តី អាចជួយមនុស្សឱ្យប្រើ និងយល់ដឹងពាក្យ/ភាសា។ ជួនកាល ពួកគេជួយមនុស្សឱ្យស្វែងរកមធ្យោបាយផ្សេងទៀត ដើម្បីប្រាស្រ័យទាក់ទង ដូចជាការប្រើឧបករណ៍បញ្ចេញសំឡេងជំនួយក្នុងការនិយាយ កុំព្យូទ័រ ទូរសព្ទដៃ វត្ថុនានា ក្តាររូបភាព កាយវិការភាសាសញ្ញា។

## Telehealth

Telehealth គឺនៅពេលអ្នកមានការណាត់ជួប ជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាពតាមទូរសព្ទ ឬការហៅតាមវីដេអូ។ GP, អ្នកឯកទេស និងបុគ្គលិកថែទាំសុខភាពជាច្រើននាក់ ផ្តល់ការប្រឹក្សាសុខភាពតាមទូរសព្ទ នៅពេលការពិនិត្យរាងកាយគឺមិនចាំបាច់ ឬមិនអាចធ្វើទៅបាន។ វាមិនជំនួសការទៅជួបវេជ្ជបណ្ឌិតផ្ទាល់នោះទេ ប៉ុន្តែអាចជាជម្រើសដ៏មានប្រយោជន៍នៅពេលដែលអ្នកមិនអាចជួបវេជ្ជបណ្ឌិតទល់មុខផ្ទាល់។

positive partnerships
Working together to support school-aged students on the autism spectrum

# Who can help?



**If you are worried about your child's development, talking to a professional may help you and your child. This information explains what different professionals do to provide support.**



## General Practitioner (GP)

A GP is a medical doctor who works with people of all ages. A GP can help with assessing physical and mental health needs for you and your child. In Australia, you often need to see your GP to get a referral to many other professionals.

## Psychologists

Psychologists (sometimes called 'psychs') can help people when they have trouble with their thinking, emotions, learning new skills or behaviour. Sometimes psychologists work with people in groups and sometimes they will talk to people by themselves. They can support parents and children with new ideas and strategies to try that might help.

## Paediatricians

Paediatricians are medical doctors who specialise in the medical care of infants, children and teenagers. They can work in hospitals or in the community. They can also refer your child to other professionals for extra support.

## Audiologists

Audiologists are specialists who can find out if people have hearing problems and can often help improve people's hearing.

## Psychiatrists

A psychiatrist is a medical doctor who specialises in mental health. Psychiatrists diagnose, treat and support mental, emotional and behavioural differences. They work in different ways and can use a combination of approaches including counselling and medication.

Go to **positivepartnerships.com.au**

The Positive Partnerships initiative is funded by the Australian Government Department of Education through the Helping Children with Autism Package. The views expressed in this publication do not necessarily represent the views of the Australian Government or the Australian Government Department of Education.

# Who can help?

## Physiotherapists

Physiotherapists (sometimes called physios) work with people of all ages when they need help with their bones, muscles, and other parts of the body. Physios can support people with specific exercises or physical aids that help them manage better.

## Occupational Therapists

Occupational Therapists (sometimes called OTs) help your child to participate in everyday activities including:

- Looking after themselves – for example: Feeding themselves, getting dressed, brushing teeth, toileting
- Taking part in activities at home, school, work and in the community – for example: Writing, using scissors, coping with sensory differences (e.g. food sensitivities, loud sounds, bright lights etc.) using public transport
- Taking part in activities they enjoy for example: Playing with others, connecting with others with similar interests. OT's can also provide tools or supports to help people take part in activities they enjoy.

## Teachers

help children learn skills like reading and writing, including children that need extra help, or learn and behave differently. Talking to the teacher can help them to plan for your child's learning.

## Social workers

Social workers can help people to cope with problems and guide them when facing challenges. Social Workers can help with managing priorities and helping people find the right supports.

## Speech Pathologists/ Therapists

Speech Pathologists help people to communicate. Communication involves more than just speaking and listening. It also involves hearing, understanding, social skills, reading, writing and using voice. Speech Pathologists can help people to use and understand words/ language. Sometimes they help people to find alternative ways to communicate such as using speech devices, computers, mobile phones, objects, picture boards, gestures, sign language.

## Telehealth

Telehealth is when you have an appointment with a healthcare provider by phone or video call. Many GPs, specialists and other healthcare workers offer a telehealth consultation when a physical examination isn't necessary or not possible. It doesn't replace visits to the doctor, but can be a helpful option when you can't see a doctor face to face.